

# អ្នកសិក្សាពហុភាសានៅរដ្ឋ Rhode Island

# កម្រងច្បាប់សិទ្ធិឯកជនរបស់សិស្ស និងគ្រួសារ

ខ្មែរ
Khmer

ខែមិថុនា ឆ្នាំ 2022

**ក្នុងនាមជាមាតាបិតា ឬអាណាព្យាបាលដែលមានកូនក្នុងវ័យសិក្សា អ្នកមានសិទ្ធិជាក់លាក់មួយចំនួននៅក្នុងសហរដ្ឋអាមេរិក ហើយស្ថិតក្រោមច្បាប់សហព័ន្ធ កូនរបស់អ្នកមានសិទ្ធិទទួលបានការអប់រំនៅសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យ-ថ្នាក់ *12* ដោយឥតគិតថ្លៃ។**

**អ្នក និងកូនរបស់អ្នកមានសិទ្ធិទាំងនេះ ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ ដើមកំណើតជាតិ ឬភាសាដែលអ្នក និងកូនរបស់អ្នកនិយាយឡើយ។ សិទ្ធិរបស់អ្នកគឺដូចគ្នា ប្រសិនបើអ្នកជាពលរដ្ឋ អ្នកស្នាក់នៅ ជនអន្តោប្រវេសន៍ ឬគ្មានឯកសារបញ្ជាក់។**

**នៅក្នុងឯកសារនេះ ក្រសួងអប់រំរដ្ឋ *Rhode Island* នឹងពន្យល់ពីសិទ្ធិធំៗបីប្រភេទ៖ សេវាកម្មភាសា ការទទួលបានការអប់រំ ហើយនិងឯកសារនិងឯកជនភាព។**



យើងសង្ឃឹមថាសិទ្ធិទាំងនេះផ្តល់អំណាចឱ្យអ្នកដើម្បីជួយគាំទ្រការរៀនសូត្ររបស់កូនអ្នក និងគាំពារពួកគេនៅពេលចាំបាច់។

អ្នកគឺជាសំឡេងរបស់កូនអ្នក ហើយអ្នកមានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយសាលារៀន និងបុគ្គលិកមណ្ឌលសាលារៀន ដើម្បីធានាថាកូនរបស់អ្នកទទួលបានការគាំទ្រ ដើម្បីឱ្យពួកគេចម្រើនលូតលាស់ទាំងផ្នែកអារម្មណ៍ សង្គម និងផ្នែកសិក្សា។

ប្រសិនបើអ្នកមានសំណួរអ្វីទាក់ទងនឹងអ្នក ឬសិទ្ធិរបស់កូនអ្នក សូមកុំស្ទាក់ស្ទើរក្នុងការទាក់ទងមកយើងនៅក្រសួងអប់រំរដ្ឋ Rhode Island
info@ride.ri.gov

# 1 សេវាកម្មភាសា



ក្នុងនាមជាមាតាបិតា **អ្នកមានសិទ្ធិមានអ្នកបកប្រែឯកសារ/អ្នកបកប្រែផ្ទាល់មាត់ដែលមាន**លក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះភាសាដែលអ្នកពេញចិត្ត សម្រាប់ការប្រាស្រ័យទាក់ទងសំខាន់ៗជាមួយនឹងមណ្ឌលសាលារៀន។

យ៉ាងណាមិញ ការទទួលបានអ្នកបកប្រែដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនគួរឱ្យអ្នកឈប់មកសាលារៀនរបស់កូនអ្នកទេ។ នៅពេលដែលអ្នកចង់និយាយជាមួយនរណាម្នាក់នៅសាលារៀន **អ្នកអាចស្នើសុំឱ្យសាលារៀនផ្តល់អ្នកបកប្រែ។** សាលារៀនមួយចំនួនមាន**អ្នកទំនាក់ទំនងមាតាបិតា** ដែលអាចធ្វើកិច្ចការនេះ។ ប្រសិនបើត្រូវការការបកប្រែ គួរមកកំណត់ពេលវេលាជាមុនដើម្បីឱ្យអ្នកមានពេលច្រើន។

**ការប្រាស្រ័យទាក់ទងសំខាន់ៗ** រួមមានជាអាទិ៍៖ ការចុះឈ្មោះចូលរៀន កម្មវិធីភាសា វគ្គសិក្សាកម្រិតខ្ពស់ ឬការអប់រំពិសេស សេវាកម្មដែលពាក់ព័ន្ធ និងកិច្ចប្រជុំគ្រូនិងមាតាបិតា ការប្រជុំ IEP សេចក្តីជូនដំណឹងអំពីវិន័យ និងគោលនយោបាយសិស្ស ទាក់ទងនឹងការមិនរើសអើង និងនីតិវិធីបណ្តឹង។

អ្នកក៏**មានសិទ្ធិទទួលព័ត៌មានដែលមានន័យពីសាលារៀនជាភាសាដែលអ្នកជ្រើសរើស និងយល់ផងដែរ។** សាលារៀនត្រូវបានតម្រូវតាមផ្លូវច្បាប់ឱ្យជូនដំណឹងដល់មាតាបិតាដែលនិយាយពហុភាសានូវព័ត៌មានដូចគ្នាដែលមាតាបិតានិយាយភាសាអង់គ្លេសទទួលអំពីកម្មវិធី សេវាកម្ម ឬសកម្មភាពនានានៅក្នុងមណ្ឌលសាលារៀន។ សាលារៀនត្រូវតែព្យាយាមបកប្រែព័ត៌មានដែលពួកគេផ្ញើទៅផ្ទះជាភាសាចម្បងរបស់គ្រួសារ ឬផ្តល់ការបកប្រែ ឱ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន។

កូនរបស់អ្នក**មានសិទ្ធិទទួលសេវាកម្មភាសា ប្រសិនបើពួកគេត្រូវការរៀនភាសាអង់គ្លេស** ហើយអ្នកត្រូវតែទទួលការជូនដំណឹងតាមផ្លូវច្បាប់អំពីកម្មវិធីទាំងនេះ។ ដើម្បីចាប់ផ្តើម **សាលារៀននឹងសុំឱ្យអ្នកបំពេញការស្ទង់មតិអំពីភាសាប្រើនៅផ្ទះ**។ នេះនឹងជួយកំណត់ថាតើកូនរបស់អ្នកត្រូវការការធ្វើតេស្តដើម្បីមើលថាគាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការបង្រៀនការអភិវឌ្ឍភាសាអង់គ្លេសឬអត់។ សាលារៀនត្រូវបានតម្រូវតាមផ្លូវច្បាប់ឱ្យកំណត់អត្តសញ្ញាណសិស្ស MLL ពីព្រោះការអភិវឌ្ឍភាសាអង់គ្លេសអាចនឹងប៉ះពាល់ដល់សិទ្ធិទទួលបានការអប់រំស្មើៗគ្នារបស់ MLL ហើយប្រសិនបើការវាយតម្លៃការពិនិត្យភាសារបស់រដ្ឋកំណត់ថាកូនរបស់អ្នកមានសិទ្ធិទទួលបានសេវាកម្មភាសាឯកទេស សាលារៀនត្រូវតែផ្តល់ការបង្រៀននេះ។

ប្រសិនបើកូនរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ កូនរបស់អ្នកត្រូវបានចាត់ចូលជា MLL ហើយ**អ្នកគួររំពឹងថានឹងទទួលបានព័ត៌មានអំពីកម្មវិធីភាសាដែលកូនរបស់អ្នកនឹងចូលរួម វិធីសាស្រ្តនៃការបង្រៀនដែលត្រូវបានប្រើនៅក្នុងកម្មវិធីដែលមានផ្សេងទៀត និងព័ត៌មានអំពីភាពខុសគ្នានៃកម្មវិធី។** អ្នកត្រូវតែទទួលការជូនដំណឹងជារៀងរាល់ឆ្នាំថាកូនរបស់អ្នកនឹងត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីអភិវឌ្ឍន៍ភាសា និងពេលណាដែលកូនរបស់អ្នកចេញពីសេវាកម្ម។ អ្នកក៏ត្រូវទទួលការជូនដំណឹងផងដែរអំពីសិទ្ធិរបស់អ្នកក្នុងការដកកូនរបស់អ្នកចេញពីកម្មវិធីអភិវឌ្ឍន៍ភាសា។

MLL: អ្នកសិក្សាពហុភាសា

# 2 ការទទួលបានការអប់រំ



កូនរបស់អ្នក**មានសិទ្ធិស្មើគ្នាក្នុងការទទួលបានកម្មវិធី និងសេវាកម្មទាំងអស់ ដែលផ្តល់ដោយមណ្ឌលសាលារៀនដែលមានសម្រាប់សិស្សផ្សេងទៀត។** កម្មវិធី និងសេវាកម្មទាំងនេះគួរតែសមស្របសម្រាប់អាយុ និងកម្រិតថ្នាក់កូនរបស់អ្នក ហើយរួមបញ្ចូលទាំងកម្មវិធីដែលតម្រូវឱ្យមានសម្រាប់ការបញ្ចប់ការសិក្សា។

កូនរបស់អ្នក**មានសិទ្ធិទទួលបានការបង្រៀនតាមមាតិកាស្នូលទាំងអស់** ដែលរួមមានមុខវិជ្ជាដូចជា អំណាន/សិល្បៈខាងភាសា គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម នៅកម្រិតសិក្សាដូចគ្នានឹងកុមារដទៃទៀតដែរ។ ក្នុងនាមជា MLL មិនគួរប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការទទួលបានការបង្រៀនតាមមាតិកាស្នូលនោះទេ។



កូនរបស់អ្នក**មានសិទ្ធិពេញលេញចំពោះសកម្មភាពក្រៅកម្មវិធីសិក្សា** (ក្លឹបក្រោយពេលរៀននៅសាលា កីឡា ជាដើម) នៅក្នុងមណ្ឌលសាលារៀន។ ក្នុងនាមជា MLL មិនគួរប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការចូលរួមសកម្មភាពក្រៅកម្មវិធីសិក្សានោះទេ។



កូនរបស់អ្នក**មានសិទ្ធិទទួលបានសេវាកម្មគាំទ្រនានាដែលស្របនឹងសេវាកម្មដែលសាលារៀន/មណ្ឌល ផ្តល់ដល់សិស្សទាំងអស់។** សេវាកម្មគាំទ្រពិសេសសម្រាប់កុមារដែលមានពិការភាពរាងកាយ ការយល់ដឹង អារម្មណ៍ និងការសិក្សា មានសម្រាប់សិស្សសាលារដ្ឋទាំងអស់។ ប្រសិនបើអ្នកជឿថាកូនរបស់អ្នកគួរទទួលបានសេវាកម្មពិសេស ប៉ុន្តែសាលារៀនមិនដឹងពីសេចក្តីត្រូវការរបស់ពួកគេ សូមទូរសព្ទទៅសាលារៀន និងស្នើសុំជំនួយ។

ជំនួយអន្តរាគមន៍មានសម្រាប់សិស្សទាំងអស់ ហើយគេច្រើនហៅថា MTSS។ **MTSS មិនមែនជាការអប់រំពិសេសទេ ប៉ុន្តែមានដើម្បីជួយសិស្សដើម្បីសម្រេចបានគោលដៅផ្នែកសិក្សា អាកប្បកិរិយា ព្រមទាំងគោលដៅផ្នែកអារម្មណ៍ និងសង្គម។**

# 3 ឯកសារ និងឯកជនភាព

**អ្នកមានសិទ្ធិចុះឈ្មោះកូនរបស់អ្នកនៅសាលារៀនដោយគេមិនចាំបាច់សុំឱ្យអ្នកផ្តល់ព័ត៌មាន ឬក្រដាសស្នាមដែលអាចនឹងបង្ហាញពីឋានៈអន្តោប្រវេសន៍របស់អ្នក ឬរបស់កូនអ្នកឡើយ។** តាមផ្លូវច្បាប់ សាលារៀនមិនត្រូវបានអនុញ្ញាតឱ្យទាមទារឯកសារដែលហាមឃាត់ ឬបង្អាក់សិស្សដោយខុសច្បាប់មិនឱ្យចុះឈ្មោះ ឬចូលរៀននោះទេ។

**សាលារៀន និងមណ្ឌលសាលារៀនអាចស្នើសុំកំណត់ត្រាចាក់ថ្នាំបង្ការនិងឯកសារបញ្ជាក់អាយុពី**គ្លីនិក ឬពីវេជ្ជបណ្ឌិត **ក៏ដូចជាភស្តុតាងបញ្ជាក់ការស្នាក់នៅ** (ដូចជាវិក្កយបត្រសេវាកម្មសាធារណៈដែលបង្ហាញនូវអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក) ទោះជាយ៉ាងណាក៏ដោយ **បុគ្គលិកមណ្ឌល ឬសាលារៀនមិនត្រូវបានអនុញ្ញាតឱ្យទាមទារឱ្យគ្រួសារណាផ្តល់លេខសន្តិសុខសង្គម ឬឯកសារអន្តោប្រវេសន៍ ដូចជា ទិដ្ឋាការ បណ្ណស្នាក់នៅ ឬភស្តុតាងបញ្ជាក់ភាពជាពលរដ្ឋឡើយ។** អ្នកមិនចាំបាច់ឆ្លើយនឹងសំណួរអំពីឋានៈអន្តោប្រវេសន៍របស់អ្នក ឬរបស់កូនអ្នកឡើយ ដូចជាសំណួរអំពីទីកន្លែងកំណើតកូនរបស់អ្នក។



សាលារៀន**សាធារណៈភាគច្រើនផ្តល់អាហារពេលព្រឹក និងអាហារថ្ងៃត្រង់បញ្ចុះតម្លៃ ឬឥតគិតថ្លៃ**សម្រាប់សិស្សដែលត្រូវការ។ អ្នកនឹងត្រូវបំពេញទម្រង់បែបបទរបស់សហព័ន្ធ ដែលស្នើឱ្យអ្នករាយនាមសមាជិកគ្រួសារ ថ្ងៃខែឆ្នាំកំណើត ទំនាក់ទំនង និងប្រាក់ចំណូលគ្រួសាររបស់អ្នក។ **អ្នកមិនចាំបាច់ត្រូវការបណ្ណសន្តិសុខសង្គមដើម្បីទទួលបានសេវាកម្មនេះទេ។**

**សាលារៀនមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកព័ត៌មានដែលអាចលាតត្រដាងនូវព័ត៌មានផ្ទាល់ខ្លួនរបស់សិស្សទេ លើកលែងតែច្បាប់អនុញ្ញាត ឬមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមាតាបិតាសិស្ស។** សិទ្ធិចំពោះឯកជនភាពត្រូវបានការពារដោយច្បាប់ដែលហៅថា FERPA ហើយច្បាប់នេះផ្តល់ឱ្យមាតាបិតានូវសិទ្ធិក្នុងការត្រួតពិនិត្យកំណត់ត្រាអប់រំនៃកូនរបស់ពួកគេនៅសាលារៀន ទទួលការពន្យល់បើចាំបាច់ ស្នើសុំព័ត៌មានថ្មីៗនិងការកែប្រែ និងឱ្យគេផ្ញើកំណត់ត្រាអប់រំរបស់កូនពួកគេទៅសាលារៀនមួយទៀតឱ្យបានទាន់ពេលវេលាប្រសិនបើពួកគេចង់ផ្ទេរសាលារៀនកូនរបស់ពួកគេ។

**យើងសូមកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់អ្នកចំពោះភាពជោគជ័យរបស់កូនអ្នក។**